ឆ្នាំ២០២២
ទំនងជាវិញ្ញាសាដ៏ស្មុគ្រស្មាញសម្រាប់កម្ពុជា

កម្ពុជា នឹងក្លាយជាប្រធានកិច្ចប្រជុំកំពូលអាស៊ាន លើកទី៣៨ នៅក្នុងឆ្នាំ២០២២ខាងមុខនេះ។ នេះបើយោងតាមមាត្រា៣១ នៃធម្មនុញ្ញអាស៊ានដែលបានចែងថា «ប្រធានអាស៊ាន ត្រូវប្តូរវេនជារៀងរាល់ឆ្នាំតាមលំដាប់អក្ខរក្រមនៃឈ្មោះជាភាសាអង់គ្លេស របស់រដ្ឋសមាជិក ហើយរដ្ឋសមាជិកដែលទទួលបានឋានៈជាប្រធានអាស៊ាននោះ ត្រូវធ្វើជាប្រធាននៃកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំមួយចំនួនទៀត» ។[9]

ក្រោយពេលបានក្លាយជាសមាជិកអាស៊ាននៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩មក ប្រទេសកម្ពុជាធ្លាប់ធ្វើជាប្រធានអាស៊ាន បានចំនួនពីរដងរួចមកហើយ ពោលគឺ លើកទី១ នៅឆ្នាំ២០០២ និងលើកទីពីរនៅឆ្នាំ២០១២។

---

[9] ASEAN, *The ASEAN Charter*, Jakarata, November 2020, P 27, available in https://asean.org/storage/November-2020-The-ASEAN-Charter-28th-Reprint.pdf, accessed in May 7,2021 at 10: am.

រូបភាពពី: https://www.londonstranger.com/south-east-asia-in-london

សម្រាប់ឆ្នាំ២០២២នេះវិញ ក្នុងនាមជាម្ចាស់ផ្ទះនិងជាប្រធាននៃកិច្ចប្រជុំនេះផងនោះ ឱកាសសម្រាប់កម្ពុជាក្នុងដំណើរការសាងសង់សហគមន៍នយោបាយ -សន្តិសុខអាស៊ានហាក់មិនមានអ្វីច្រើនទេ ព្រោះតំបន់នេះមានខ្នងបង្អែកផ្សេងគ្នា និងកម្មវិធីនយោបាយស្មុគស្មាញក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន។ ដូចជាប្រទេស សិង្គបុរី គឺជាប្រជាធិបតេយ្យបែបផ្តាច់ការ, ប្រទេសវៀតណាមនិងឡាវ គឺ

ជាប្រទេសប្រកាន់យករបបកុម្មុយនីយស្ត៍ឯកបក្ស, ភូមាគឺជាប្រទេសប្រជាធិបតេយ្យបន្តដោយភាពផុយស្រួយ ហើយហ្វ៊ីលីពីន ជាប្រជាធិបតេយ្យដោយរងការចោទប្រកាន់ច្រើនពីបស្ចឹមប្រទេសក្រោមកណ្តាប់ដៃដែកកម្ទេចការជួញដូរគ្រឿងញៀនរបស់លោកប្រធានាធិបតី ឌុយ ទែតេ អំពីការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ, ចំណែកឥណ្ឌូណេសុីវិញទើបតែស្គាល់នូវលទ្ធិប្រជាធិបតេយ្យពេញលេញ ក្រោយការដួលរលំនៃរបបគ្រប់គ្រង ផ្តាច់ការរបស់លោកស៊ូហាតូនាខែឧសភា ឆ្នាំ១៩៩៨ [๒] ចំណែកឯប្រទេសកម្ពុជា ថៃ ព្រុយណេ និង៉ម៉ាឡេសុី គឺជាប្រទេសដែលប្រកាន់យករបបរាជានិយម។ ទោះបីជាប្រទេសទាំងបួន ប្រកាន់របបនយោបាយរាជានិយមដូចគ្នាក្តី តែប្រព័ន្ធនៃការដឹកនាំរបៀបនៃការគ្រងរាជ្យសម្បត្តិនិងជាពិសេសនោះ តួនាទីនៅ

---

[๒] ជឹង ប៉ូជីន, *៦០ឆ្នាំក្រោយមក ឥណ្ឌូណេសុីពិចារណាពីកេរ្តឹដំណែលនៃការធ្វើកំណែទម្រង់របស់ខ្លួន*, វិទ្យុសំលេងសហរដ្ឋអាម៉េរិក (VOA), ចុះផ្សាយថ្ងៃ ទី 25 ឧសភា 2018, https://khmer.voanews.com/a/indonesia-consider-reforming/4409455.html។

ក្នុងនយោបាយគឺមានលក្ខណៈ ខុសគ្នាពីប្រទេសមួយ ទៅ ប្រទេសមួយ។

កម្ពុជានិងថៃប្រទេសទាំងពីរ កំពុងអនុវត្តរបប រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងការសម្រេចផ្សេងៗ ត្រូវឆ្ងងកាត់សភា។ សម្រាប់ប្រទេសកម្ពុជាព្រះមហាក្សត្រ ទ្រង់គ្រងរាជ្យសម្បត្តិ ប៉ុន្តែមិនកាន់អំណាចឡើយ។ ឯប្រទេសថៃ ក៏មានលក្ខណៈស្រដៀងទៅនឹងកម្ពុជាផងដែរ ពោលគឺនៅប្រទេសថៃ ព្រះមហាក្សត្រគឺ ជាប្រមុខរដ្ឋនិង ជាអគ្គមេបញ្ជាការកំពូលកងទ័ពថៃផងដែរ ។

ដោយឡែក ប្រទេសព្រុយណោ ក៏ជាប្រទេសប្រ កាន់របបរាជានិយមដែរ តែមានលក្ខណៈខុសដាច់ស្រឡះ ពីប្រទេសទាំងពីរខាងលើ (កម្ពុជានិងថៃ) ដោយសារតែ ប្រទេសព្រុយណោប្រកាន់របបរាជានិយមផ្តាច់ការ ដែល មិនបានកំណត់ច្បាស់លាស់ នៅក្នុងរដ្ឋធម្មនុញ្ញរបស់ ព្រុយណោទេ។ បន្ថែមពីនេះទៅទៀតព្រះមហាក្សត្រមាន តួនាទីពីររួមមាន៖ ជាប្រមុខរដ្ឋផង (ស្តេច) និងជាប្រមុខ រដ្ឋាភិបាលផង(នាយករដ្ឋមន្ត្រី)។ ហើយក្នុងនោះការ

សម្រេចផ្សេងៗត្រូវធ្វើកាត់ការសម្រេចពីព្រះមហាក្សត្រ ជាមុនសិន។

នៅប្រទេសម៉ាឡេស៊ីវិញ ប្រទេសនេះជាប្រទេសដែលប្រកាន់របបរាជាសហព័ន្ធ ក្នុងនោះព្រះមហាក្សត្រម៉ាឡេស៊ី ត្រូវជ្រើសរើសចេញពីស្តេចនៅក្នុងរដ្ឋទាំងប្រាំបួនរបស់ម៉ាឡេស៊ីដោយធ្វើកាត់ការបោះឆ្នោតពីក្រុមប្រឹក្សារាជសម្បត្តិម៉ាឡេ។ បន្ថែមពីលើនេះ ព្រះមហាក្សត្រម៉ា-ឡេស៊ីមានអាណត្តិត្រឹមតែ៥ឆ្នាំប៉ុណ្ណោះ ហើយត្រូវផ្ទាស់ប្តូរទៅតាមអក្ខរក្រមនៃឈ្មោះរបស់រដ្ឋទាំងប្រាំបួន រួមមាន Johor, Kedah, Kelantan, Negri Sembilan, Pahang, Perak, Perlis, Selangor និង Treng។ ប៉ុន្តែបេក្ខជនដែលឈរឈ្មោះជាព្រះមហាក្សត្រ អាចឈរឈ្មោះបានម្តងទៀតនៅពេលដែលអាណត្តិនៃព្រះមហាក្សត្រដល់រដ្ឋរបស់ខ្លួន។[៣]

---

[៣] ថ្មីៗ៖ អាស៊ាន៖ ប្រទេសប្រកាន់របបរាជានិយមដូចគ្នា តែការអនុវត្តខុសគ្នា , ចុះផ្សាយថ្ងៃទី៦ កុម្ភៈ ២០១៥, available in: https://thmeythmey.com/?page=detail&id=23080, accessed on May 7, 2021 at 15: 30 pm។

ការណ៍នេះ នឹងរុញច្រានអាស៊ានឱ្យធ្លាក់ចូលបន្តិចម្តងៗនៃការរង្គោះរង្គើផ្នែកនយោបាយនិងសន្តិសុខនៅក្នុងតំបន់តាំងពីអតីតកាលក៏ដូចជាបច្ចុប្បន្នកាលផងដែរ ក្រោមហេតុផលចំនួន៣យ៉ាងដូចខាងក្រោម៖

ហេតុផលទី១ ទីតាំងភូមិសាស្ត្រ ជាការពិតណាស់អាស៊ាន ជាតំបន់ កណ្តាលក្នុងការភ្ជាប់រវាង មហាសមុទ្រឥណ្ឌានិងម ហាសមុទ្រប៉ាស៊ីហ្វិច និងជាតំបន់ឆ្លងកាត់ផ្លូវទឹកយ៉ាងសំខាន់ពីតំបន់អាស៊ីទៅអាហ្វ្រិក និងទៅតំបន់អាស៊ីខាងត្បូងៗ



រូបភាពពី៖ https://www.google.com/search?

ហេតុផលទី២ គឺកត្តាប្រជាសាស្ត្រដែលក្នុងតំបន់អាស៊ានទាំងមូលមានប្រជាជនសរុបជាង៦៥៥លាននាក់ [4] ដែលជាតំបន់មានសក្តានុពលខាងទីផ្សារ និងកម្លាំងពលកម្ម។

ហេតុផលទី៣ គឺកត្តាសេដ្ឋកិច្ច ក្រៅពីភោគផលធនធានធម្មជាតិ អាស៊ានជាតំបន់មួយដែលមានសក្តានុ-ពលខ្លាំងលើផ្លូវនាវាចរណ៍ដឹកទំនិញ ម្យ៉ាងវិញទៀតអាស៊ានក៏ជាប្រជាជាតិ ដែលកំពុងស្រេកឃ្លានការអភិវឌ្ឍខ្លាំង ហើយបើនិយាយពីកំណើន ផលិតផលក្នុងស្រុកសរុប (GDP) វិញក្នុងឆ្នាំ២០២០ អាស៊ានមានរហូតដល់ ៣.១១ ទ្រីលានដុល្លារអាម៉េរិក។[5]

---

[4] startista, *Total population of the ASEAN countries from 2010 to 2020,* available in https://www.statista.com/ statistics/ 796245/gdp-of-the-asean- countries/, accessed on May 7, 2021 at 15: 30 pm។

[5] startista, *Gross domestic product of the ASEAN countries from 2010 to 2020*, available in https://www. statista.com/statistics/796245/gdp-of-the-asean-countries/, accessed on May 7, 2021 at 15: 30 pm។

គឺដោយសារកត្តាទាំងនោះហើយ ដែលអាស៊ាននៅតែរក្សាបានភាពជាកូនក្រមុំដែលមហាអំណាចតំបន់ ក៏ដូចជាមហាអំណាចពិភពលោកតែងចិញ្ចឹមចិត្តចង់បាន និងចង់មានតួនាទីឈរជើងរឹងមាំក្នុងតំបន់នេះ ទាំងក្នុងអតីតកាលក៏ដូចជាបច្ចុប្បន្នកាល។

ពិតមែនហើយ អាស៊ានជាសហគមន៍មួយដែលនៅមានការប្រទាញប្រទង់គ្នាច្រើនលើទិដ្ឋភាពភូមិសាស្ត្រនយោបាយយ៉ាងស្ទូចស្រាលណាស់ បើទោះបីសង្ត្រាមត្រជាក់បានផុតរលត់ទៅមែន ប៉ុន្តែស្រមោលវានៅតែខ្ចាំងឬអាចនិយាយបានថា ការប្រកួតប្រជែងនៅតែមាន ប៉ុន្តែស្តែងឡើងក្រោមរូបភាពបំភ័ន្តភ្នែកផ្សេងៗរបស់មហាអំណាចតំបន់និងពិភពលោក សកម្មភាពទាំងនោះស្តែងឱ្យឃើញតាមរយៈនៃការរះឡើងឥទ្ធិពលចិនក្រោមគោល នយោបាយផ្ទូវនិងខ្សែក្រវាត់របស់លោកប្រធានាធិបតីស៊ីជីនពីង យុទ្ធ-សាស្ត្រឥណ្ឌូ-ប៉ាស៊ីហ្វិក ដែលជាគោលនយោបាយទប់ទល់ចិនរបស់សហរដ្ឋអាម៉ែរិក, ជប៉ុននិងសម្ព័ន្ធមិត្ត ដូចជាឥណ្ឌា និងអូស្ត្រាលីជាដើម, គោលនយោបាយសម្ងឹងមកទិសខាងត្បូងរបស់លោកមូន ជេអ៊ីន ដែលសំដៅលើអាស៊ាន

និងឥណ្ឌា, អាស៊ានបូក៣ រួមមានអាស៊ាន ចិន ជប៉ុននិង
កូរ៉ែខាងត្បូង, កិច្ចព្រមព្រៀងនៃកិច្ចសហប្រតិបត្តិការ
មេគង្គ និងប្រទេសជាសមាជិកអាស៊ានដែលនៅអមតាម
បណ្តោយដងទន្ទេមេគង្គ ព្រមទាំងកិច្ចព្រមព្រៀងផ្សេងៗ
ទៀតៗ នេះបង្ហាញឱ្យឃើញថា អាស៊ានជាអង្គការតំបន់
ដែលពិបាកនឹងរក្សាគោលជំហរខ្ជួនឯងបានណាស់ហើយ
ប្រធានអាស៊ានក៏ពិបាកនិងរកការសម្របសម្រួលមួយដែរៗ

រូបភាពពីៈ https://www.facebook.com/aseansecretariat/photos/a.10150347651743854/10156665013078854/?type=3&theater

ជាងនេះទៅទៀត តាមរយៈបទពិសោធន៍នៅឆ្នាំ ២០១២ កន្ធងមក, កម្ពុជាធ្លាប់រងការចោទប្រកាន់ដែលថា កម្ពុជាបានរាំងខ្ទប់មិនអាចចេញសេចក្តីថ្លែងការណ៍រួមបានដែលកាលនោះមានតួអង្គពីរដែលចេញមុខខ្លាំងគឺ មានប្រទេសវៀតណាម និងហ្វ៊ីលីពីន។

សម្រាប់ឆ្នាំក្រោយនេះ គេត្រូវមើលតួអង្គហ្វីលីពីនសិន មុននឹងឈានទៅរកការសន្និដ្ឋានមួយដែលថា តើប្រធានាធិបតីហ្វ៊ីលីពីនអាណត្តិថ្មីនេះ(ចោះឆ្នោតនៅខែ ឧសភាឆ្នាំ២០២២) នឹងមានទំនោរទៅរកចិនឬអាម៉ែរិកបើងាកទៅរកចិន នោះនឹងមិនសូវដុតរោលបញ្ហាសមុទ្រចិនខ្លាំងនោះទេ តែបើជាអ្នកអាម៉ែរិកនិយមវិញ គឺច្បាស់ណាស់ កំដៅនឹងឡើងពិសេសក្នុងពេលកម្ពុជា ជាប្រធានអាស៊ាននេះតែម្តង។ រយៈពេលនេះ ហ្វ៊ីលីពីន កំពុងស្វែងរកអនាគតមេដឹកនាំថ្មីក្នុងឆ្នាំ២០២២ ហើយចិនក៏ហាក់កំពុងលូកដៃចូលដោយប្រយោលដែរ គឺថ្មីៗនេះកងជីវ

ពលចិនជាង២០០នាវា [៦] បានបណ្តែតខ្ជួនចូលទៅដល់តំបន់ថ្មប៉ប្រះទឹកកៀកនឹងហ្វីលីពីន ដែលជាប្រធានបទនៃកម្មវិធីនយោបាយការបរទេសសម្រាប់អនាគប្រធានាធិបតីថ្មីៗ

ប្រភព៖ https://www.bbc.com/news/world-asia-56474847

---

[៦] ឈាង បុជ្ជា,ហ្វីលីពីនចោទចិនថា បានបញ្ជូននាវាជាង២០០ទៅបង្កើតទីតាំងយោធាក្នុងដែនទឹករបស់ហ្វីលីពីន, វិទ្យុបារាំងអន្តរជាតិ ចុះផ្សាយថ្ងៃទី២១ ខែមីនា ២០២១, available in : https://www.rfi.fr/km accessed on May 7, 2021 at 15: 30 pmៗ

ក្រៅពីកត្តាប្រកួតប្រជែងខាងភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចនៅមានវិបត្តិកូវីដ-១៩ មួយទៀតក៏ជារឿងស្មុគ-ស្មាញណាស់ដែរ ថ្មីត្បិតតែវាជាវិបត្តិសាកលមែន តែវាក៏បានជះផលវិបាកមិនតិចទេមកដល់ប្រទេសជាសមាជិកអាស៊ាន ត្បិតជំងឺនេះកំពុងញាំញីខ្លាំងនៅអាស៊ានបើទោះបីជាយុទ្ធនាការចាក់វ៉ាក់សាំងកំពុងមានសកម្មភាពនៅក្នុងសមាគមន៍ទាំងមូលក្តី។

ដាកចេញពីបញ្ហាប្រាក់ស្រែះទាំងអស់នោះ បើយើងក្រឡេកមកមើលជ្រុងនៃផលប្រយោជន៍និងឱកាសសម្រាប់កម្ពុជា ដែលអាចទាញចេញក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០២២នេះវិញ យើងអាចសន្និដ្ឋានបានថា ជាឱកាសក្នុងការបង្ហាញឱ្យពិភពលោក បានស្គាល់ពីកម្ពុជាបន្ថែមទៀតពីលើអ្វីដែលធ្លាប់មានកន្ទងមក, ជាការបង្ហាញពីសក្តានុពលលើសេដ្ឋកិច្ចក្នុងការទាក់ទាញអ្នកវិនិយោគបន្ថែម, ការប្រជុំដែលបង្ហាញថា កម្ពុជាអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងជំងឺកូវីដ-១៩ ដែលជាការបើកទំព័រផ្សព្វផ្សាយថ្មីដល់ភ្ញៀវទេសចរអន្តជាតិនានា ឱ្យមក

កម្សាន្ត នៅកម្ពុជាបាន(ក្នុងការណីប្រជុំផ្ទាល់ មិនមែនតាម អនឡាញ)។

រីឯចំពោះទិដ្ឋភាព នយោបាយតំបន់ ផលចំណេញ គឺកម្ពុជា អាចមានកេរ្តឹ៍ឈ្មោះមួយបន្ថែមទៀតលើធាកអន្តរ ជាតិ ដោយអាចសិក្សាលទ្ធភាពដើរតួនាទីជាអ្នកសម្រប សម្រួល ក្នុងយន្តការស្វែងរកដំណោះស្រាយជូនវិប ត្តិនៅ ភូមា ដោយយោងតាមបទពិសោធន៍កម្ពុជាក្នុងឆ្នាំ១៩៩១ គឺ ថា កម្ពុជាមិនអាចធ្វើអ្វីបានលើសនេះបានព្រោះធម្មនុញ្ញ អាស៊ានបានចងរួចបាត់ទៅហើយគឺ ការដែលមិនជ្រៀតចូល កិច្ចការផ្ទៃក្នុងផងគ្នា, ដោយឡែកបញ្ហាសន្តិសុខតំបន់វិញ កម្ពុជាអាចប្រហែលបានត្រឹមចូលរួមជាមួយតំបន់ និងពិភព លោកក្នុងការប្រយុទ្ធប្រឆាំង និងភេវរកម្ម និងការជួញដូរ មនុស្ស, ឧក្រិដ្ឋកម្មឆ្ងងដែនជាដើម។ ប៉ុន្តែបើអាចកម្ពុជាគួរ សិក្សាលទ្ធភាពក្នុ ងការរក្សាជំហរកណ្តាលនិយមមួយដើរតួរ ជាមេអណ្តើកក្នុ ងការសម្របសម្រួលបន្ធូរបន្ថយកំដៅនៅ សមុទ្រចិនខាងត្បូង ដើម្បីចាប់យកឱកាសទាំងនោះ ការ ត្រៀមខ្ជូនរបស់កម្ពុជារួមមានៈ ការគ្រប់គ្រងការរីករាលដាល កូវីដ-១៩ ឱ្យបាននៅក្នុងប្រទេស, កំណែទម្រង់បន្ថែមបន្ធូរ-

បន្ទយលក្ខខណ្ឌដល់អ្នកវិនិយោគបរទេស ពិសេសកាត់បន្ទយការិយាធិបតេយ្យ, កែសម្រួលតំបន់ទេសចរណ៍ក្នុងស្រុកទាំងសោភ័ណ្ឌភាព, សេវាកម្ម និងបរិស្ថាន។ ជាមួយគ្នានេះដែរ កម្ពុជាគួរសិក្សាលទ្ធភាពក្នុងការបង្កើតក្រុមការងារពិសេសមួយដើម្បីបញ្ចុះបញ្ចូលបណ្តាគូជម្លោះនៅកូមា និងក្រុមពិសេសមួយទៀត សម្រាបសម្រួលបណ្តាប្រទេសដែលមានជម្លោះជាមួយចិន និងប្រទេសចិន ដើម្បីជជែកគ្នារកដំណោះស្រាយមុនសិន។ ប្រសិនបើការជជែកមិនត្រូវគ្នា និង គ្មានការសម្ប្ទានគ្នាទេនោះ ជម្រើសល្អបំផុតគឺបន្តរក្សាជំហរតាមឆ្នាំ២០១២។

ជារួមមក ក្នុងឆ្នាំ២០២២នេះ កម្ពុជាប្រហែលជាអាចនឹងទទួលដុំថ្មក្តៅដែលអាស៊ានបោះមកជុំ វិញបញ្ហាសមុទ្រចិនខាងត្បូងដូចឆ្នាំ២០១២ដែរ។ មួយវិញទៀត បញ្ហានៃការប្រកួតប្រជែងឥទ្ធិពលនយោបាយ របស់មហាអំណាចតំបន់ និងពិភពលោកក្នុងអាស៊ាន, វិបត្តិនៅកូមា និងវិបត្តិកូវីដ១៩ ជាដើម ដែលសុទ្ធសឹងជាវិញ្ញាសាដែលពិបាកនឹងរកដំណោះស្រាយបានសម្រាប់កម្ពុជា ក្នុងនាមជាប្រធាននៃកិច្ចប្រជុំកំពូលអាស៊ានឆ្នាំ២០២២នេះ។